# ប្រវត្តិរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបានបង្កើតឡើងយោងតាមព្រះរាជក្រិត្យលេខ នស/រកត ០២/០១/០៣៦ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ ។ ព្រះរាជក្រិត្យនេះបានកំណត់ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដោយមានអក្សរកាត់ ក.ជ.ក.ស ។ ក.ជ.ក.ស ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើបញ្ហា ដែលទាក់ទងដល់ការលើកកំពស់ស្ថានភាព តួនាទីរបស់ស្ត្រី និងសុខមាលភាពសង្គមស្ត្រីកម្ពុជា សំដៅកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងស្ត្រី និងអំពើហិង្សាលើស្ត្រី ។

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានសមាសភាព:**

| | | |
|---|---|---|
| ១. សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ | | ព្រះប្រធានកិតិយស |
| ២. សម្តេចនាយករដ្ឋមន្ត្រី | | អនុប្រធានកិត្តិយស |
| ៣. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | | ប្រធាន |
| ៤. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ រូប | ជាអនុប្រធាន |
| ៥. រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១ រូប | ជាអនុប្រធាន |
| ៦. រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ១ រូប | ជាសមាជិក |
| ៧. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| ៨. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១ រូប | ជាសមាជិក |
| ៩. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ រូប | ជាសមាជិក |
| ១១. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | ជាសមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១ រូប | ជាសមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ រូប | ជាសមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | ជាសមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១ រូប | ជាសមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងព័ត៌មាន | ១ រូប | ជាសមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងផែនការ | ១ រូប | ជាសមាជិក |
| ១៨. រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ រូប | ជាសមាជិក |
| ១៩. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| ២០. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១ រូប | ជាសមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ១ រូប | ជាសមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | ១ រូប | ជាសមាជិក |

២៣. រដ្ឋលេខាធិការក្រសួងបរិស្ថាន ១ រូប ជាសមាជិក

២៤. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ១ រូប ជាសមាជិក

២៥. អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៏ ១ រូប ជាសមាជិក

២៦. អនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១ រូប ជាសមាជិក

២៧. អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ១ រូប ជាសមាជិក

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានភារកិច្ចៈ**

- ជួយរាជរដ្ឋាភិបាលក្នុងការសម្របសម្រួល តាមដាន វាយតម្លៃនៃការអនុវត្ត និងផ្តល់អនុសាសន៏ ក្នុងគោលបំណងគាំទ្រ និងជម្រុញការអនុវត្តគោលនយោបាយជាតិ ច្បាប់ បទបញ្ញា និងវិធានការដែលទាក់ទងដល់ ការលើកកំពស់ ស្ថានភាពតួនាទី និងសុខមាលភាពសង្គមស្ត្រីកម្ពុជា ។
- ជួយរាជរដ្ឋាភិបានក្នុងការតាមដានការអនុវត្តសន្ធិសញ្ញាអន្តរជាតិនានា ពាក់ព័ន្ធទៅនឹងសិទ្ធិនារី និងការអនុវត្តច្បាប់ជាតិដែលទាក់ទងដល់ការទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងបទបញ្ញត្តិច្បាប់នានាដែលទាក់ទងដល់ស្ត្រី ដើម្បីផ្តល់យោបល់ លើកអនុសាសន៏ ឬសុំធ្វើវិសោធនកម្ម តាមករណីជាក់ស្តែង ដើម្បីធ្វើអោយស្ថានភាពស្ត្រីកាន់តែប្រសើរឡើង ។
- សម្របសម្រួលការរៀបចំរបាយការណ៏ជាតិ ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីនៅព្រះរាជាណាចក្រកម្ពុជា និងពិនិត្យ ផ្តល់យោបល់ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ សម្រេចមុននឹងផ្ញើទៅអង្គការសហប្រជាជាតិ ។
- តាមដាន និងជម្រុញការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ និងក្នុងកម្មវិធីអភិវឌ្ឍន៏ជាតិរបស់រាជរដ្ឋាភិបាល ។
- រៀបចំរបាយការណ៏ប្រចាំឆ្នាំ ស្តីពីសកម្មភាពដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានបំពេញ ដើម្បីផ្ញើជូនរាជរដ្ឋាភិបាល ។
- ទទួលភារកិច្ចផ្សេងៗទៀតតាមសំនូមពររបស់រាជរដ្ឋាភិបាល

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក.ជ.ក.ស ត្រូវមានអគ្គលេខាធិការដ្ឋានអចិន្រ្តៃយ៏មួយសេនាធិការ ដែលមានទីតាំងនៅទីស្តីការក្រសួងកិច្ចការនារី ហើយការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្រ្តៃយ៏ ក.ជ.ក.ស នឹងកំណត់ដោយអនុក្រិត្យ ។ អគ្គលេខាធិការដ្ឋានអចិន្រ្តៃយ៏ ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើអនុរដ្ឋលេខាធិការ អមដោយអគ្គលេខាធិការមួយចំនួន ដែលមានឋានៈស្មើអគ្គនាយករងដែលផ្ទេរមកបម្រើការងារជាអចិន្រ្តៃយ៏នៅអគ្គលេខាធិការដ្ឋានអចិន្រ្តៃយ៏ ក.ជ.ក.ស និងមានមន្ត្រីមួយចំនួនទៀតផ្ទេរមកបម្រើការងារជាអចិន្រ្តៃយ៏ នៅអគ្គលេខាធិការដ្ឋាន ។

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...*៥៧*.... អនក្រ.បក ចុះថ្ងៃទី ..*០៧*... ខែ ..មិថុនា... ឆ្នាំ២០០៧

**ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក.ជ.ក.ស**

**អង្គការលេខ**

**របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី**

